# របាយការណ៍ស្ថិតិហិរញ្ញវត្ថុរដ្ឋាភិបាលថ្នាក់ជាតិ
# ប្រចាំខែតុលា ឆ្នាំ ២០១៨

*(បណ្ដោះអាសន្ន)*

**មាតិកា** **ទំព័រ**


| | |
|---|---|
| ១.សេចក្ដីសង្ខេប | ១ |
| ២.តារាងស្ថិតិ | |
| ២.១.ប្រតិបត្តិការហិរញ្ញវត្ថុរដ្ឋាភិបាល | ២ |
| ២.២.តារាងស្ថិតិចំណូល | ៣ |
| ២.៣.តារាងស្ថិតិចំណាយ | ៥ |
| ២.៤.តារាងស្ថិតិបម្រែបម្រួលទ្រព្យសកម្ម/បំណុល | ៦ |
| ៣.ក្រាហ្វិក | ៧ |
| ៤.ឧបសម្ព័ន្ធស្ថិតិហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ | ៩ |
| ៥.សេចក្ដីសង្ខេបអំពី "ក្របខ័ណ្ឌស្តង់ដារស្ថិតិហិរញ្ញវត្ថុរដ្ឋាភិបាល" | ១០ |

## ១.សេចក្តីសង្ខេប

## ស្តីពីការអនុវត្តថវិកា ខែតុលា ឆ្នាំ ២០១៨

1. **ការអនុវត្តចំណូល÷** ក្នុងខែតុលា ឆ្នាំ២០១៨នេះ ចំណូលរដ្ឋបាលថ្នាក់ជាតិអនុវត្តបាន **១ ៥៦៣ ៥២០** លានរៀល គឺបានកើនឡើង **៣,៥៦%** ឬស្មើនឹង ៥៣ ៧៧៥ លានរៀល បើធៀបនឹងខែតុលាឆ្នាំ២០១៧។ ក្នុងរយៈពេល១០ខែ ឆ្នាំ២០១៨នេះ ចំណូលរដ្ឋបាលថ្នាក់ជាតិសរុបអនុវត្តបាន **១៦ ០៨៤ ៤១៨** លានរៀលឬស្មើនឹង ៨៩,២៣% នៃច្បាប់ហិរញ្ញវត្ថុឆ្នាំ២០១៨ ឬបានកើនឡើង **៨,១២%** បើធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៧។ ចំណូលនេះត្រូវបានគាំទ្រដោយ ចំណូលពន្ធប្រមាណ ៨៤,២៧% ចំណូលផ្សេងៗនិងចំណូលពីអំណោយប្រមាណ ១៥,៧៣%។

2. **ចំណាយសរុប÷** ក្នុងខែតុលាឆ្នាំ២០១៨នេះ ចំណាយសរុបរដ្ឋបាលថ្នាក់ជាតិអនុវត្តបាន **១ ៤០៤ ១៨៧** លានរៀល គឺបានថយចុះ **២៥,២០%** ឬស្មើនឹង ៤៧៣ ០២៩ លានរៀល បើធៀបទៅនឹងខែតុលាឆ្នាំ២០១៧។ ក្នុងរយៈពេល ១០ខែ ឆ្នាំ២០១៨នេះ ចំណាយសរុបអនុវត្តបាន **១៤ ៧៣២ ៧៧៤** លានរៀល ឬស្មើនឹង **៦៦,៩៨%** នៃច្បាប់ហិរញ្ញវត្ថុឆ្នាំ២០១៨ បានកើនឡើង **៦,២៣%** បើធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៧។ ក្នុងចំណាយសរុបនេះ រួមមាន**ចំណាយ** (expense) សម្រេចបាន **៧៤,៦៩% និងទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ** (net acquisition of non-financial assets) សម្រេចបាន **៥២.៩០%** នៃច្បាប់ហិរញ្ញវត្ថុឆ្នាំ២០១៨។

3. **តុល្យភាពប្រតិបត្តិការដុល** (ចំណូលដកចំណាយ)÷ គិតត្រឹមខែតុលាឆ្នាំ២០១៨នេះ តុល្យភាពប្រតិបត្តិការដុល មានសមតុល្យចំនួន **៥ ៤៧១ ១៤២** លានរៀលឬបាន**ថយចុះ** ០,៣៦% បើធៀបទៅនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០១៧។ ចំណែកឯ ***សមតុល្យនៃការឲ្យខ្ចី/ខ្ចីប្រាក់កម្ចីសុទ្ធ*** (ចំណូលដកចំណាយសរុប) គិតត្រឹមខែតុលាឆ្នាំ ២០១៨នេះ មានសមតុល្យចំនួន **១ ៣៥១ ៦៤៥** លានរៀល ដែលក្នុងនោះមានទ្រព្យសកម្មហិរញ្ញវត្ថុសុទ្ធសរុប ចំនួន ១ ៩២៤ ៦៩៧ លានរៀល និងបំណុលសរុបបានកើនឡើងចំនួន ៥៨៥ ៥៥៥ លានរៀល។

4. **សន្និដ្ឋាន÷** សម្រាប់ខែតុលាឆ្នាំ២០១៨នេះ ការអនុវត្តថវិកាហាក់មិនសូវទទួលបានលទ្ធផលល្អប្រសើរដូចកាលពីខែកញ្ញាកន្លងទៅដោយការប្រមូលចំណូលសរុបបានកើនឡើងត្រឹមតែ **៣,៥៦%** និងការអនុវត្តចំណាយបានធ្លាក់ចុះ **២៦,១០%** ស្របពេលដែលទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ (ការវិនិយោគ) បានថយចុះ **២២,១៦%** បើធៀបទៅនឹងខែតុលាឆ្នាំ២០១៧។ តែបើពិនិត្យមើលការអនុវត្តក្នុងរយៈពេល១០ខែឆ្នាំ២០១៨នេះវិញ ថវិការដ្ឋបាលថ្នាក់ជាតិ **នៅតែមានភាពល្អប្រសើរ**ដែលបង្ហាញបានតាមរយៈចំណូល និងចំណាយសរុបកើនឡើងប្រមាណ **៨,១២%** និង **៦,២៣%** រៀងគ្នា សម្របពេលដែលបំណុលកើនឡើងសុទ្ធបានថយចុះ**៤៩,៨០%** បើធៀបនឹងការអនុវត្តក្នុងរយៈពេលដូចគ្នានាឆ្នាំ២០១៧។ ជាមួយគ្នានេះ តុល្យភាពប្រតិបត្តិការដុលនៃថវិការដ្ឋបាលថ្នាក់ជាតិមានចំនួនសរុប ៥ ៤៧១ ១៤២ លានរៀល ឬស្មើនឹង **៥,១៥ដង** នៃចំណាយក្នុងខែតុលាឆ្នាំ២០១៨ តែក៏ត្រូវជំរុញល្បឿននៃការអនុវត្តចំណាយបន្ទុកបុគ្គលិក និងទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ (គម្រោងវិនិយោគ)។

# ២.១. ប្រតិបត្តិការហិរញ្ញវត្ថុរដ្ឋាភិបាល

ឯកតា÷ លានរៀល

| 0.515499866 | | ច្បាប់ឆ្នាំ ២០១៨ | អនុវត្តន៍ ២០១៨ | អនុ/ច្ប ២០១៨ | ប្រចាំខែ មករា | ប្រចាំខែ កុម្ភៈ | ប្រចាំខែ មីនា | ប្រចាំខែ មេសា | ប្រចាំខែ ឧសភា | ប្រចាំខែ មិថុនា | ប្រចាំខែ កក្កដា | ប្រចាំខែ សីហា | ប្រចាំខែ កញ្ញា | ប្រចាំខែ តុលា | ប្រចាំខែ វិច្ឆិកា | ប្រចាំខែ ធ្នូ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | វិធីសាស្ត្រគណនេយ្យ | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash |
| **1** | **ចំណូល** | **18,026,105.0** | **16,084,418.4** | **89.23%** | **1,293,788.8** | **1,346,388.3** | **1,813,434.0** | **1,998,491.1** | **1,725,159.3** | **1,570,103.7** | **1,499,726.2** | **1,720,561.9** | **1,553,245.0** | **1,563,520.1** | **0.0** | **0.0** |
| 11 | ពន្ធ | 14,814,568.0 | 13,554,247.5 | 91.49% | 1,119,312.2 | 1,140,239.1 | 1,653,275.7 | 1,604,629.9 | 1,427,704.5 | 1,363,401.3 | 1,198,952.4 | 1,472,977.1 | 1,274,831.5 | 1,298,923.9 | 0.0 | 0.0 |
| 13 | អំណោយ | 716,102.0 | 670,372.3 | 93.61% | 49,258.5 | 49,258.5 | 58,224.8 | 72,131.9 | 150,755.6 | 60,270.6 | 49,258.5 | 49,468.6 | 82,486.8 | 49,258.5 | ... | ... |
| 14 | ចំណូលផ្សេងៗ | 2,495,435.0 | 1,859,798.5 | 74.53% | 125,218.1 | 156,890.7 | 101,933.4 | 321,729.3 | 146,699.1 | 146,431.8 | 251,515.4 | 198,116.3 | 195,926.7 | 215,337.6 | ... | ... |
| **2** | **ចំណាយ** | **14,209,516.0** | **10,613,276.0** | **74.69%** | **598,763.3** | **991,699.9** | **1,016,607.3** | **928,359.0** | **1,127,955.2** | **1,089,574.0** | **1,385,338.2** | **1,223,760.9** | **1,182,930.6** | **1,068,287.7** | **...** | **...** |
| 21 | បន្ទុកបុគ្គលិក | 7,002,828.9 | 5,616,036.2 | 80.20% | 457,742.4 | 499,001.0 | 567,747.9 | 531,646.2 | 570,046.3 | 605,655.7 | 647,725.3 | 580,319.5 | 668,956.2 | 487,195.7 | ... | ... |
| 22 | ទំនិញ និងសេវាកម្ម | 3,122,211.4 | 1,769,785.4 | 56.68% | 42,110.0 | 39,564.2 | 78,300.7 | 133,807.8 | 224,856.7 | 170,519.7 | 288,392.1 | 328,507.2 | 192,430.7 | 271,296.3 | ... | ... |
| 24 | ការប្រាក់ | 387,481.0 | 329,628.3 | 85.07% | 26,400.5 | 57,738.6 | 57,697.5 | 11,758.8 | 13,953.2 | 3,081.8 | 27,096.6 | 83,791.6 | 37,644.9 | 10,464.8 | ... | ... |
| 25 | ឧបត្ថម្ភកធន | 10,920.0 | 10,484.7 | 96.01% | 0.0 | 0.0 | 0.0 | 0.0 | 5,206.7 | 0.0 | 5,278.0 | 0.0 | 0.0 | 0.0 | ... | ... |
| 26 | អំណោយ | 1,217,274.4 | 1,154,838.4 | 94.87% | 991.9 | 298,149.7 | 52,122.5 | 174,505.9 | 50,276.2 | 32,773.3 | 203,541.7 | 110,133.7 | 39,739.5 | 192,604.2 | ... | ... |
| 27 | ឧបត្ថម្ភសង្គមកិច្ច | 1,484,210.5 | 1,146,697.6 | 77.26% | 62,800.5 | 78,463.1 | 132,842.3 | 49,262.2 | 222,644.5 | 158,456.4 | 162,328.0 | 83,035.5 | 119,094.1 | 77,771.0 | ... | ... |
| 28 | ចំណាយផ្សេងៗ | 984,589.8 | 585,805.5 | 59.50% | 8,718.0 | 18,783.3 | 127,896.4 | 27,378.1 | 40,971.6 | 119,087.2 | 50,976.5 | 37,973.4 | 125,065.3 | 28,955.7 | ... | ... |
| ***GOB*** | ***តុល្យភាពប្រតិបត្តិការដុល*** | **3,816,589.0** | **5,471,142.4** | **143.35%** | **695,025.5** | **354,688.4** | **796,826.7** | **1,070,132.1** | **597,204.1** | **480,529.7** | **114,388.1** | **496,801.0** | **370,314.4** | **495,232.4** | **0.0** | **0.0** |
| ***NOB*** | ***តុល្យភាពប្រតិបត្តិការសុទ្ធ*** | **3,816,589.0** | **5,471,142.4** | **143.35%** | **695,025.5** | **354,688.4** | **796,826.7** | **1,070,132.1** | **597,204.1** | **480,529.7** | **114,388.1** | **496,801.0** | **370,314.4** | **495,232.4** | **0.0** | **0.0** |
| **31** | **ទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុសុទ្ធ** | 7,787,598.1 | 4,119,497.9 | 52.90% | 274,265.3 | 176,453.4 | 476,787.5 | 464,378.3 | 312,553.7 | 311,557.5 | 790,622.6 | 685,647.5 | 291,332.7 | 335,899.4 | ... | ... |
| 311 | ទ្រព្យអចលត៍ | 7,787,594.1 | 3,331,623.3 | 42.78% | 274,265.3 | 163,255.2 | 427,778.5 | 410,684.2 | 255,094.8 | 257,529.7 | 500,550.3 | 441,482.7 | 281,799.3 | 319,183.3 | ... | ... |
| 314 | ទ្រព្យសកម្មគ្មានផលិតភាព | 4.0 | 787,874.6 | | 0.0 | 13,198.2 | 49,009.0 | 53,694.1 | 57,458.8 | 54,027.8 | 290,072.4 | 244,164.8 | 9,533.4 | 16,716.1 | ... | ... |
| ***2M*** | ***ចំណាយសរុប*** | 21,997,114.1 | 14,732,773.9 | 66.98% | 873,028.6 | 1,168,153.3 | 1,493,394.7 | 1,392,737.3 | 1,440,508.9 | 1,401,131.5 | 2,175,960.8 | 1,909,408.4 | 1,474,263.3 | 1,404,187.1 | 0.0 | 0.0 |
| ***NLB*** | ***សមតុល្យនៃការអោយខ្ចី/ប្រាក់កម្ចី*** | **-3,971,009.1** | **1,351,644.5** | **...** | **420,760.2** | **178,235.0** | **320,039.2** | **605,753.8** | **284,650.4** | **168,972.2** | **-676,234.6** | **-188,846.5** | **78,981.7** | **159,333.0** | **0.0** | **0.0** |
| **32** | **ទ្រព្យហិរញ្ញវត្ថុសុទ្ធ** | -180,193.0 | 1,924,697.2 | ... | 526,243.0 | 166,643.1 | 471,250.6 | 744,706.7 | 352,181.7 | 284,660.8 | -680,949.5 | -161,370.5 | -618.8 | 221,950.2 | 0.0 | 0.0 |
| 321 | ក្នុងប្រទេស | -180,193.0 | 1,924,697.2 | ... | 526,243.0 | 166,643.1 | 471,250.6 | 744,706.7 | 352,181.7 | 284,660.8 | -680,949.5 | -161,370.5 | -618.8 | 221,950.2 | 0.0 | 0.0 |
| **33** | **បំណុលសុទ្ធ** | 3,343,444.0 | 585,554.8 | 17.51% | 105,482.8 | -11,591.7 | 151,394.5 | 138,952.7 | 67,533.0 | 115,860.9 | -4,689.3 | 29,562.5 | -81,863.5 | 74,913.1 | 0.0 | 0.0 |
| 332 | ក្រៅប្រទេស | 3,343,444.0 | 585,554.8 | 17.51% | 105,482.8 | -11,591.7 | 151,394.5 | 138,952.7 | 67,533.0 | 115,860.9 | -4,689.3 | 29,562.5 | -81,863.5 | 74,913.1 | 0.0 | 0.0 |

ថ្ងៃ ខែកត្តិក ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០១៨
**អគ្គនាយក**
**អគ្គនាយកដ្ឋានគោលនយោបាយ**

ថ្ងៃ ខែកត្តិក ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០១៨
**ប្រធាននាយកដ្ឋាន**
**នាយកដ្ឋានស្ថិតិ និងវិភាគសេដ្ឋកិច្ច**

ថ្ងៃ ខែកត្តិក ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០១៨
**ប្រធានការិយាល័យ**
**ស្ថិតិហិរញ្ញវត្ថុសាធារណៈ**

# ២.២.តារាងស្ថិតិចំណូល

ឯកតា៖ លានរៀល

| | | ច្បាប់ឆ្នាំ ២០១៨ | អនុវត្តន៍ ២០១៨ | អនុ/ច្ប ២០១៨ | ប្រចាំខែ មករា | ប្រចាំខែ កុម្ភៈ | ប្រចាំខែ មីនា | ប្រចាំខែ មេសា | ប្រចាំខែ ឧសភា | ប្រចាំខែ មិថុនា | ប្រចាំខែ កក្កដា | ប្រចាំខែ សីហា | ប្រចាំខែ កញ្ញា | ប្រចាំខែ តុលា | ប្រចាំខែ វិច្ឆិកា | ប្រចាំខែ ធ្នូ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | វិធីសាស្ត្រគណនេយ្យ | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash |
| **1** | **ចំណូល** | 18,026,105.0 | 16,084,418.4 | 89.23% | 1,293,788.8 | 1,346,388.3 | 1,813,434.0 | 1,998,491.1 | 1,725,159.3 | 1,570,103.7 | 1,499,726.2 | 1,720,561.9 | 1,553,245.0 | 1,563,520.1 | 0.0 | 0.0 |
| **11** | **ពន្ធ** | 14,814,568.0 | 13,554,247.5 | 91.49% | 1,119,312.2 | 1,140,239.1 | 1,653,275.7 | 1,604,629.9 | 1,427,704.5 | 1,363,401.3 | 1,198,952.4 | 1,472,977.1 | 1,274,831.5 | 1,298,923.9 | 0.0 | 0.0 |
| **111** | **ពន្ធលើប្រាក់ចំណូល និងប្រាក់ចំណេញ** | 3,899,306.0 | 3,271,064.4 | 83.89% | 234,780.5 | 176,185.1 | 567,838.6 | 667,474.9 | 364,824.5 | 247,267.3 | 264,636.6 | 287,275.7 | 251,815.9 | 208,965.4 | ... | ... |
| 1111 | ពន្ធរូបវន្តបុគ្គល | 1,170,000.0 | 700,226.6 | 59.85% | 74,225.5 | 73,451.5 | 71,824.7 | 89,352.0 | 56,991.8 | 73,040.1 | 67,513.1 | 69,440.2 | 66,406.9 | 57,980.7 | ... | ... |
| 1112 | ពន្ធនីតិបុគ្គល | 2,729,306.0 | 2,570,837.8 | 94.19% | 160,554.9 | 102,733.6 | 496,013.9 | 578,122.9 | 307,832.7 | 174,227.2 | 197,123.4 | 217,835.5 | 185,409.0 | 150,984.7 | ... | ... |
| **114** | **ពន្ធលើទំនិញ និងសេវាប្រើប្រាស់** | 8,786,262.0 | 8,409,645.1 | 95.71% | 727,301.9 | 793,204.1 | 897,916.4 | 760,160.7 | 851,854.2 | 928,059.3 | 761,146.2 | 940,841.8 | 860,027.4 | 889,133.3 | ... | ... |
| 1141 | ពន្ធទូទៅលើទំនិញ និងសេវាប្រើប្រាស់ | 4,812,262.0 | 4,426,539.1 | 91.98% | 372,677.9 | 360,245.0 | 462,475.6 | 393,637.7 | 448,842.1 | 525,410.6 | 424,174.8 | 476,602.1 | 506,318.2 | 456,155.1 | ... | ... |
| 11411 | អាករលើតម្លៃបន្ថែម | 4,812,262.0 | 4,426,460.6 | 91.98% | 372,676.7 | 360,244.9 | 462,469.5 | 393,637.0 | 448,842.0 | 525,397.4 | 424,174.8 | 476,582.2 | 506,317.8 | 456,118.5 | ... | ... |
| 11413 | ពន្ធលើផលរបរ និងពន្ធលើទំនិញ និងសេវាកម្មផ្សេងៗ | 0.0 | 78.5 | ... | 1.2 | 0.1 | 6.1 | 0.8 | 0.1 | 13.2 | 0.0 | 19.9 | 0.4 | 36.6 | ... | ... |
| 1142 | អាករពិសេស | 3,974,000.0 | 3,983,106.0 | 100.23% | 354,624.0 | 432,959.1 | 435,440.8 | 366,522.9 | 403,012.1 | 402,648.7 | 336,971.3 | 464,239.6 | 353,709.2 | 432,978.2 | ... | ... |
| **115** | **ពន្ធលើពាណិជ្ជកម្មអន្តរជាតិ** | 2,120,500.0 | 1,863,331.7 | 87.87% | 157,127.8 | 170,393.1 | 185,350.0 | 174,557.3 | 210,690.3 | 187,015.9 | 171,294.6 | 244,587.5 | 162,815.9 | 199,499.2 | ... | ... |
| 1151 | អាករ និងបន្ទុកនាំចូលផ្សេងៗ | 2,075,200.0 | 1,823,573.1 | 87.87% | 149,667.4 | 166,600.8 | 182,124.0 | 172,186.7 | 206,977.6 | 184,018.2 | 167,275.8 | 240,036.2 | 159,001.3 | 195,685.2 | ... | ... |
| 1152 | ពន្ធនាំចេញ | 45,300.0 | 39,758.6 | 87.77% | 7,460.4 | 3,792.3 | 3,226.0 | 2,370.6 | 3,712.7 | 2,997.7 | 4,018.8 | 4,551.4 | 3,814.7 | 3,814.1 | ... | ... |
| **116** | **ពន្ធផ្សេងៗ** | 8,500.0 | 10,206.2 | 120.07% | 102.0 | 456.7 | 2,170.7 | 2,436.9 | 335.6 | 1,058.8 | 1,875.0 | 272.1 | 172.3 | 1,326.0 | ... | ... |
| **13** | **អំណោយ** | 716,102.0 | 670,372.3 | 93.61% | 49,258.5 | 49,258.5 | 58,224.8 | 72,131.9 | 150,755.6 | 60,270.6 | 49,258.5 | 49,468.6 | 82,486.8 | 49,258.5 | ... | ... |
| **131** | **អំណោយពីរដ្ឋាភិបាលអន្តរជាតិ** | 295,551.0 | 256,337.5 | 86.73% | 24,629.3 | 24,629.3 | 24,629.3 | 24,629.3 | 24,629.3 | 34,674.3 | 24,629.3 | 24,629.3 | 24,629.3 | 24,629.3 | ... | ... |
| 1311 | ចរន្ត | ... | 10,045.0 | ... | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 10,045.0 | 0.0 | 0.0 | 0.0 | ... | ... | ... |
| 1312 | មូលធន | 295,551.0 | 246,292.5 | 83.33% | 24,629.3 | 24,629.3 | 24,629.3 | 24,629.3 | 24,629.3 | 24,629.3 | 24,629.3 | 24,629.3 | 24,629.3 | 24,629.3 | ... | ... |
| **132** | **អំណោយពីអង្គការអន្តរជាតិ** | 420,551.0 | 414,034.8 | 98.45% | 24,629.3 | 24,629.3 | 33,595.6 | 47,502.6 | 126,126.4 | 25,596.4 | 24,629.3 | 24,839.3 | 57,857.6 | 24,629.3 | ... | ... |
| 1321 | ចរន្ត | ... | 210.1 | ... | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 210.1 | 0.0 | ... | ... | ... |
| 1322 | មូលធន | 420,551.0 | 413,824.8 | 98.40% | 24,629.3 | 24,629.3 | 33,595.6 | 47,502.6 | 126,126.4 | 25,596.4 | 24,629.3 | 24,629.3 | 57,857.6 | 24,629.3 | ... | ... |
| **14** | **ចំណូលផ្សេងៗ** | 2,495,435.0 | 1,859,798.5 | 74.53% | 125,218.1 | 156,890.7 | 101,933.4 | 321,729.3 | 146,699.1 | 146,431.8 | 251,515.4 | 198,116.3 | 195,926.7 | 215,337.6 | ... | ... |
| **141** | **ចំណូលពីទ្រព្យសម្បត្តិ** | 197,844.5 | 254,476.9 | 128.62% | 4,637.0 | 2,758.4 | 9,075.6 | 146,142.3 | 10,612.4 | 9,953.8 | 18,058.8 | 21,357.3 | 4,709.9 | 27,171.5 | ... | ... |
| 1411 | ចំណូលការប្រាក់ | 82,526.0 | 89,673.3 | 108.66% | 0.0 | 0.0 | 7,116.6 | 26,332.5 | 2,193.4 | 7,250.9 | 13,670.8 | 13,169.6 | 1,323.4 | 18,616.0 | ... | ... |
| 14112 | ចំណូលការប្រាក់ក្នុងប្រទេស | 82,526.0 | 89,673.3 | 108.66% | 0.0 | 0.0 | 7,116.6 | 26,332.5 | 2,193.4 | 7,250.9 | 13,670.8 | 13,169.6 | 1,323.4 | 18,616.0 | ... | ... |
| 1412 | ចំណូលភាគលាភ | 19,450.0 | 101,194.4 | 520.28% | 0.0 | 0.0 | 0.0 | 97,035.3 | 0.0 | 18.5 | 187.3 | 359.1 | 2,254.8 | 1,339.5 | ... | ... |
| 1413 | ចំណូលផលទុននៃសេវាផ្គត់ផ្គង់ (អគ្គិសនី, ទឹក...) | 33.1 | 53.3 | 161.05% | 0.0 | 0.0 | 10.5 | 0.0 | 12.9 | 0.0 | 0.0 | 14.7 | 0.0 | 15.3 | ... | ... |

# ២.២.តារាងស្ថិតិចំណូល

ឯកតា÷ លានរៀល

| | | ច្បាប់ឆ្នាំ ២០១៨ | អនុវត្តន៍ ២០១៨ | អនុ/ច្ប ២០១៨ | ប្រចាំខែ មករា | ប្រចាំខែ កុម្ភៈ | ប្រចាំខែ មីនា | ប្រចាំខែ មេសា | ប្រចាំខែ ឧសភា | ប្រចាំខែ មិថុនា | ប្រចាំខែ កក្កដា | ប្រចាំខែ សីហា | ប្រចាំខែ កញ្ញា | ប្រចាំខែ តុលា | ប្រចាំខែ វិច្ឆិកា | ប្រចាំខែ ធ្នូ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | វិធីសាស្រ្តគណនេយ្យ | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash |
| 1415 | ចំណូលពីការជួល | 95,835.4 | 63,555.8 | 66.32% | 4,637.0 | 2,758.4 | 1,948.5 | 22,774.5 | 8,406.1 | 2,684.4 | 4,200.7 | 7,813.8 | 1,131.7 | 7,200.7 | ... | ... |
| **142** | **ចំណូលពីការលក់ទំនិញ និងសេវាកម្ម** | 2,026,307.7 | 1,430,142.8 | 70.58% | 115,718.3 | 141,827.4 | 81,842.6 | 166,605.5 | 125,952.4 | 98,899.3 | 220,878.9 | 153,172.4 | 153,124.2 | 172,121.9 | ... | ... |
| 1421 | ចំណូលពីការលក់ក្នុងទីផ្សារ | 556,997.0 | 326,818.2 | 58.68% | 3,783.6 | 23,855.5 | 19,228.6 | 33,999.0 | 36,905.3 | 53,202.4 | 17,043.2 | 45,542.7 | 72,355.7 | 20,902.1 | ... | ... |
| 1422 | ចំណូលសេវារដ្ឋបាល | 967,018.4 | 716,481.5 | 74.09% | 61,047.6 | 66,630.2 | 60,880.3 | 76,104.7 | 56,266.2 | 13,473.6 | 149,176.5 | 67,698.0 | 49,797.5 | 115,406.8 | ... | ... |
| 1423 | ចំណូលពីការលក់ ឬសកម្មភាពផ្សេងៗ (ទេសចរណ៍, វប្បធម៌...) | 502,292.3 | 386,843.2 | 77.02% | 50,887.0 | 51,341.7 | 1,733.7 | 56,501.8 | 32,780.9 | 32,223.3 | 54,659.2 | 39,931.7 | 30,971.0 | 35,813.0 | ... | ... |
| **143** | **ចំណូលបានពីការពិន័យ** | 146,549.8 | 142,766.7 | 97.42% | 4,647.9 | 12,091.7 | 8,003.1 | 8,613.8 | 9,545.4 | 10,555.7 | 12,094.3 | 23,295.0 | 37,992.0 | 15,927.8 | ... | ... |
| **144** | **ការផ្ទេរផ្សេងៗដែលមិនបានញែក** | 124,733.0 | 32,412.1 | 25.99% | 214.8 | 213.2 | 3,012.2 | 367.8 | 588.9 | 27,023.1 | 483.3 | 291.7 | 100.6 | 116.4 | ... | ... |
| 1441 | ចរន្ត | 124,733.0 | 32,412.1 | 25.99% | 214.8 | 213.2 | 3,012.2 | 367.8 | 588.9 | 27,023.1 | 483.3 | 291.7 | 100.6 | 116.4 | ... | ... |
| 14412 | ផ្សេងៗ | 124,733.0 | 32,412.1 | 25.99% | 214.8 | 213.2 | 3,012.2 | 367.8 | 588.9 | 27,023.1 | 483.3 | 291.7 | 100.6 | 116.4 | ... | ... |

# ២.៣.តារាងស្ថិតិចំណាយ

ឯកតា÷ លានរៀល

| | | ច្បាប់ឆ្នាំ ២០១៨ | អនុវត្តន៍ ២០១៨ | អនុ/ច្បា ២០១៨ | ប្រចាំខែ មករា | ប្រចាំខែ កុម្ភៈ | ប្រចាំខែ មីនា | ប្រចាំខែ មេសា | ប្រចាំខែ ឧសភា | ប្រចាំខែ មិថុនា | ប្រចាំខែ កក្កដា | ប្រចាំខែ សីហា | ប្រចាំខែ កញ្ញា | ប្រចាំខែ តុលា | ប្រចាំខែ វិច្ឆិកា | ប្រចាំខែ ធ្នូ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | វិធីសាស្ត្រគណនយ្យ | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash |
| **2** | **ចំណាយ** | **14,209,516.0** | **10,613,276.0** | **74.69%** | **598,763.3** | **991,699.9** | **1,016,607.3** | **928,359.0** | **1,127,955.2** | **1,089,574.0** | **1,385,338.2** | **1,223,760.9** | **1,182,930.6** | **1,068,287.7** | **...** | **...** |
| **21** | **បន្ទុកបុគ្គលិក** | **7,002,828.9** | **5,616,036.2** | **80.20%** | **457,742.4** | **499,001.0** | **567,747.9** | **531,646.2** | **570,046.3** | **605,655.7** | **647,725.3** | **580,319.5** | **668,956.2** | **487,195.7** | **...** | **...** |
| **211** | **ប្រាក់ខែ** | 7,002,828.9 | 5,616,036.2 | 80.20% | 457,742.4 | 499,001.0 | 567,747.9 | 531,646.2 | 570,046.3 | 605,655.7 | 647,725.3 | 580,319.5 | 668,956.2 | 487,195.7 | ... | ... |
| **22** | **ទំនិញ និងសេវាកម្ម** | **3,122,211.4** | **1,769,785.4** | **56.68%** | **42,110.0** | **39,564.2** | **78,300.7** | **133,807.8** | **224,856.7** | **170,519.7** | **288,392.1** | **328,507.2** | **192,430.7** | **271,296.3** | **...** | **...** |
| **24** | **ការប្រាក់** | **387,481.0** | **329,628.3** | **85.07%** | **26,400.5** | **57,738.6** | **57,697.5** | **11,758.8** | **13,953.2** | **3,081.8** | **27,096.6** | **83,791.6** | **37,644.9** | **10,464.8** | **...** | **...** |
| **241** | **បំណុលក្រៅប្រទេស** | 387,481.0 | 329,460.6 | 85.03% | 26,400.5 | 57,738.6 | 57,697.5 | 11,758.8 | 13,785.5 | 3,081.8 | 27,096.6 | 83,791.6 | 37,644.9 | 10,464.8 | ... | ... |
| **242** | **បំណុលក្នុងស្រុកមិនមែនរដ្ឋាភិបាល** | 0.0 | 167.7 | ... | 0.0 | 0.0 | 0.0 | 0.0 | 167.7 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | ... | ... |
| **25** | **ការឧបត្ថម្ភធន** | **10,920.0** | **10,484.7** | **96.01%** | **0.0** | **0.0** | **0.0** | **0.0** | **5,206.7** | **0.0** | **5,278.0** | **0.0** | **0.0** | **0.0** | **...** | **...** |
| **251** | **សហគ្រាស សាធារណៈ** | 10,920.0 | 10,484.7 | 96.01% | 0.0 | 0.0 | 0.0 | 0.0 | 5,206.7 | 0.0 | 5,278.0 | 0.0 | 0.0 | 0.0 | ... | ... |
| **26** | **អំណោយ** | **1,217,274.4** | **1,154,838.4** | **94.87%** | **991.9** | **298,149.7** | **52,122.5** | **174,505.9** | **50,276.2** | **32,773.3** | **203,541.7** | **110,133.7** | **39,739.5** | **192,604.2** | **...** | **...** |
| **262** | **អង្គការអន្តរជាតិ** | 162,847.3 | 62,002.5 | 38.07% | 112.8 | 6,496.9 | 4,310.5 | 8,836.5 | 13,270.5 | 4,241.9 | 5,957.6 | 6,595.3 | 842.7 | 11,337.9 | ... | ... |
| 2621 | ចរន្ត | 162,847.3 | 62,002.5 | 38.07% | 112.8 | 6,496.9 | 4,310.5 | 8,836.5 | 13,270.5 | 4,241.9 | 5,957.6 | 6,595.3 | 842.7 | 11,337.9 | ... | ... |
| **263** | **រដ្ឋាភិបាលដទៃទៀត (រដ្ឋាបាលថ្នាក់ក្រោមជាតិ,...)** | 1,054,427.1 | 1,092,835.9 | 103.64% | 879.1 | 291,652.9 | 47,811.9 | 165,669.4 | 37,005.7 | 28,531.3 | 197,584.1 | 103,538.4 | 38,896.8 | 181,266.3 | ... | ... |
| 2631 | ចរន្ត | 1,054,427.1 | 1,092,835.9 | 103.64% | 879.1 | 291,652.9 | 47,811.9 | 165,669.4 | 37,005.7 | 28,531.3 | 197,584.1 | 103,538.4 | 38,896.8 | 181,266.3 | ... | ... |
| **27** | **ឧបត្ថម្ភសង្គមកិច្ច** | **1,484,210.5** | **1,146,697.6** | **77.26%** | **62,800.5** | **78,463.1** | **132,842.3** | **49,262.2** | **222,644.5** | **158,456.4** | **162,328.0** | **83,035.5** | **119,094.1** | **77,771.0** | **...** | **...** |
| **271** | **អត្ថប្រយោជន៍សន្តិសុខសង្គម** | 1.2 | ... | ... | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | ... | ... | ... |
| **272** | **អត្ថប្រយោជន៍ជំនួយសង្គម** | 488,098.4 | 337,759.9 | 69.20% | 749.9 | 782.6 | 27,808.9 | 5,347.8 | 138,346.2 | 64,619.4 | 70,107.6 | 6,590.3 | 13,502.8 | 9,904.3 | ... | ... |
| **273** | **អត្ថប្រយោជន៍សង្គមសម្រាប់មន្ត្រីរាជការ** | 996,110.9 | 808,937.7 | 81.21% | 62,050.6 | 77,680.4 | 105,033.3 | 43,914.3 | 84,298.4 | 93,836.9 | 92,220.4 | 76,445.2 | 105,591.4 | 67,866.7 | ... | ... |
| **28** | **ចំណាយផ្សេងៗ** | **984,589.8** | **585,805.5** | **59.50%** | **8,718.0** | **18,783.3** | **127,896.4** | **27,378.1** | **40,971.6** | **119,087.2** | **50,976.5** | **37,973.4** | **125,065.3** | **28,955.7** | **...** | **...** |
| **282** | **ការផ្ទេរផ្សេងៗដែលមិនបានបែងចែក** | 984,589.8 | 585,805.5 | 59.50% | 8,718.0 | 18,783.3 | 127,896.4 | 27,378.1 | 40,971.6 | 119,087.2 | 50,976.5 | 37,973.4 | 125,065.3 | 28,955.7 | ... | ... |
| 2821 | ចរន្ត | 984,589.8 | 585,805.5 | 59.50% | 8,718.0 | 18,783.3 | 127,896.4 | 27,378.1 | 40,971.6 | 119,087.2 | 50,976.5 | 37,973.4 | 125,065.3 | 28,955.7 | ... | ... |
| **283** | **បុព្វលាភធានារ៉ាប់រង, និងផ្សេងៗ** | 1,588.1 | 622.6 | 39.20% | 0.0 | 0.0 | 183.5 | 0.0 | 1.4 | 172.7 | 25.6 | 59.4 | 175.8 | 4.2 | ... | ... |
| 2831 | បុព្វលាភធានារ៉ាប់រងចរន្ត | 1,588.1 | 622.6 | 39.20% | 0.0 | 0.0 | 183.5 | 0.0 | 1.4 | 172.7 | 25.6 | 59.4 | 175.8 | 4.2 | ... | ... |
| 28311 | បុព្វលាភធានារ៉ាប់រង | 1,588.1 | 622.6 | 39.20% | 0.0 | 0.0 | 183.5 | 0.0 | 1.4 | 172.7 | 25.6 | 59.4 | 175.8 | 4.2 | ... | ... |

# ២.៤.តារាងស្ថិតិបម្រែបម្រួលទ្រព្យសកម្ម/បំណុល

ឯកតា÷ លានរៀល

| | | ច្បាប់ឆ្នាំ ២០១៨ | អនុវត្តន៍ ២០១៨ | អនុ/ច្ប ២០១៨ | ប្រចាំខែ មករា | ប្រចាំខែ កុម្ភៈ | ប្រចាំខែ មីនា | ប្រចាំខែ មេសា | ប្រចាំខែ ឧសភា | ប្រចាំខែ មិថុនា | ប្រចាំខែ កក្កដា | ប្រចាំខែ សីហា | ប្រចាំខែ កញ្ញា | ប្រចាំខែ តុលា | ប្រចាំខែ វិច្ឆិកា | ប្រចាំខែ ធ្នូ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | វិធីសាស្រ្តគណនយ្យ | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash |
| **3** | **បំរែបំរួលតម្លៃសុទ្ធនៃទ្រព្យកម្ម** | **4,263,961.1** | **5,458,640.3** | **128.02%** | **695,025.5** | **354,688.3** | **796,643.5** | **1,070,132.3** | **597,202.5** | **480,357.4** | **114,362.4** | **494,714.5** | **372,577.4** | **482,936.5** | **...** | **...** |
| **31** | **ទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុសុទ្ធ** | **7,787,598.1** | **4,119,497.9** | **52.90%** | **274,265.3** | **176,453.4** | **476,787.5** | **464,378.3** | **312,553.7** | **311,557.5** | **790,622.6** | **685,647.5** | **291,332.7** | **335,899.4** | **...** | **...** |
| **311** | **អចលនទ្រព្យ** | 7,787,594.1 | 3,331,623.3 | 42.78% | 274,265.3 | 163,255.2 | 427,778.5 | 410,684.2 | 255,094.8 | 257,529.7 | 500,550.3 | 441,482.7 | 281,799.3 | 319,183.3 | ... | ... |
| **311A** | ***ការទិញ÷ អចលនទ្រព្យ*** | 7,787,597.1 | 3,331,623.3 | 42.78% | 274,265.3 | 163,255.2 | 427,778.5 | 410,684.2 | 255,094.8 | 257,529.7 | 500,550.3 | 441,482.7 | 281,799.3 | 319,183.3 | ... | ... |
| **311B** | ***ការលក់÷ អចលនទ្រព្យ*** | 3.0 | ... | ... | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | ... | ... | ... |
| 3111 | អាគារ និងសំណង់ផ្សេងៗ | 7,472,736.0 | 3,054,197.4 | 40.87% | 161,363.0 | 163,188.6 | 421,332.7 | 396,728.8 | 238,827.5 | 246,988.8 | 449,337.4 | 428,193.2 | 261,755.8 | 286,481.6 | ... | ... |
| 3111A | *ការទិញ÷ អាគារ និងសំណង់ផ្សេងៗ* | 7,472,739.0 | 3,054,197.4 | 40.87% | 161,363.0 | 163,188.6 | 421,332.7 | 396,728.8 | 238,827.5 | 246,988.8 | 449,337.4 | 428,193.2 | 261,755.8 | 286,481.6 | ... | ... |
| 3111B | *ការលក់÷ អាគារ និងសំណង់ផ្សេងៗ* | 3.0 | ... | ... | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | ... | ... | ... |
| 3112 | ម៉ាស៊ីន និងសម្ភារបរិក្ខា | 314,858.1 | 277,425.9 | 88.11% | 112,902.2 | 66.6 | 6,445.8 | 13,955.4 | 16,267.4 | 10,540.9 | 51,212.8 | 13,289.6 | 20,043.5 | 32,701.7 | ... | ... |
| 3112A | *ការទិញ÷ ម៉ាស៊ីន និងសម្ភារបរិក្ខា* | 314,858.1 | 277,425.9 | 88.11% | 112,902.2 | 66.6 | 6,445.8 | 13,955.4 | 16,267.4 | 10,540.9 | 51,212.8 | 13,289.6 | 20,043.5 | 32,701.7 | ... | ... |
| **314** | **ទ្រព្យសកម្មគ្មានផលិតភាព** | 4.0 | 787,874.6 | | 0.0 | 13,198.2 | 49,009.0 | 53,694.1 | 57,458.8 | 54,027.8 | 290,072.4 | 244,164.8 | 9,533.4 | 16,716.1 | ... | ... |
| **314A** | ***ការទិញ÷ ទ្រព្យសកម្មគ្មានផលិតភាព*** | 4.0 | 787,874.6 | | 0.0 | 13,198.2 | 49,009.0 | 53,694.1 | 57,458.8 | 54,027.8 | 290,072.4 | 244,164.8 | 9,533.4 | 16,716.1 | ... | ... |
| 3141 | ដី | 4.0 | 787,874.6 | | 0.0 | 13,198.2 | 49,009.0 | 53,694.1 | 57,458.8 | 54,027.8 | 290,072.4 | 244,164.8 | 9,533.4 | 16,716.1 | ... | ... |
| 3141A | *ការទិញ÷ ដី* | 4.0 | 787,874.6 | | 0.0 | 13,198.2 | 49,009.0 | 53,694.1 | 57,458.8 | 54,027.8 | 290,072.4 | 244,164.8 | 9,533.4 | 16,716.1 | ... | ... |
| **32** | **ទ្រព្យសកម្មហិរញ្ញវត្ថុសុទ្ធ** | **-180,193.0** | **1,924,697.2** | **...** | **526,243.0** | **166,643.1** | **471,250.6** | **744,706.7** | **352,181.7** | **284,660.8** | **-680,949.5** | **-161,370.5** | **-618.8** | **221,950.2** | **...** | **...** |
| 3202 | រូបិយប័ណ្ណ និងប្រាក់បញ្ញើ | 0.0 | 2,086,925.5 | ... | 526,243.0 | 166,643.1 | 484,134.0 | 775,317.0 | 352,181.7 | 311,347.5 | -642,501.6 | -138,818.0 | 2,886.7 | 249,492.0 | ... | ... |
| 3204 | កម្ចី | -180,193.0 | -130,295.0 | ... | 0.0 | 0.0 | -12,883.5 | -28,833.2 | 0.0 | -16,591.9 | -18,397.8 | -22,772.6 | -3,505.5 | -27,310.5 | ... | ... |
| 3205 | ដើមទុន និងមូលនិធិភាគហ៊ុន | 0.0 | -31,933.2 | ... | 0.0 | 0.0 | 0.0 | -1,777.0 | 0.0 | -10,094.9 | -20,050.0 | 220.0 | 0.0 | -231.3 | ... | ... |
| **321** | **ក្នុងស្រុក** | -180,193.0 | 1,924,697.2 | ... | 526,243.0 | 166,643.1 | 471,250.6 | 744,706.7 | 352,181.7 | 284,660.8 | -680,949.5 | -161,370.5 | -618.8 | 221,950.2 | ... | ... |
| 3212 | រូបិយប័ណ្ណ និងប្រាក់បញ្ញើ | 0.0 | 2,086,925.5 | ... | 526,243.0 | 166,643.1 | 484,134.0 | 775,317.0 | 352,181.7 | 311,347.5 | -642,501.6 | -138,818.0 | 2,886.7 | 249,492.0 | ... | ... |
| 3214 | កម្ចី | -180,193.0 | -130,295.0 | ... | 0.0 | 0.0 | -12,883.5 | -28,833.2 | 0.0 | -16,591.9 | -18,397.8 | -22,772.6 | -3,505.5 | -27,310.5 | ... | ... |
| 3215 | ដើមទុន និងមូលនិធិភាគហ៊ុន | 0.0 | -31,933.2 | ... | 0.0 | 0.0 | 0.0 | -1,777.0 | 0.0 | -10,094.9 | -20,050.0 | 220.0 | 0.0 | -231.3 | ... | ... |
| **33** | **បំណុលសុទ្ធ** | **3,343,444.0** | **585,554.8** | **17.51%** | **105,482.8** | **-11,591.7** | **151,394.5** | **138,952.7** | **67,533.0** | **115,860.9** | **-4,689.3** | **29,562.5** | **-81,863.5** | **74,913.1** | **...** | **...** |
| 3304 | កម្ចី | 3,343,444.0 | 585,554.8 | 17.51% | 105,482.8 | -11,591.7 | 151,394.5 | 138,952.7 | 67,533.0 | 115,860.9 | -4,689.3 | 29,562.5 | -81,863.5 | 74,913.1 | ... | ... |
| **332** | **ក្រៅស្រុក** | 3,343,444.0 | 585,554.8 | 17.51% | 105,482.8 | -11,591.7 | 151,394.5 | 138,952.7 | 67,533.0 | 115,860.9 | -4,689.3 | 29,562.5 | -81,863.5 | 74,913.1 | ... | ... |
| 3324 | កម្ចី | 3,343,444.0 | 585,554.8 | 17.51% | 105,482.8 | -11,591.7 | 151,394.5 | 138,952.7 | 67,533.0 | 115,860.9 | -4,689.3 | 29,562.5 | -81,863.5 | 74,913.1 | ... | ... |

# ៣. ក្រាហ្វិក


ក្រាហ្វិកទី ១÷ សូចនាករសំខាន់ៗនៃប្រតិបត្តិការរដ្ឋាភិបាល
ឯកតា÷ ពិតជាប៊ីលានរៀល
3,000
2,000
1,000
0
-1,000
-2,000
-3,000
មករា
មេសា
កក្កដា
តុលា
ចំណូល{២០១៨}
ចំណាយ{២០១៨}
ទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុសុទ្ធ{២០១៨}
ទ្រព្យសកម្មហិរញ្ញវត្ថុសុទ្ធ{២០១៨}
បំណុលសុទ្ធ{២០១៨}


ក្រាហ្វិកទី ២÷ ចំណូល (ពន្ធ អំណោយ និងផ្សេងៗ)
ឯកតា÷ ពិតជាប៊ីលានរៀល
2,500
2,000
1,500
1,000
500
0
មករា
មេសា
កក្កដា
តុលា
ចំណូលពន្ធ ២០១៨
អំណោល ២០១៨
ចំណូលផ្សេងៗ ២០១៨
ចំណូលពន្ធ ២០១៧
ចំណូលអំណោយ ២០១៧
ចំណូលផ្សេងៗ ២០១៧


ក្រាហ្វិកទី ៣÷ ចំណូលពន្ធ
ឯកតា÷ ពិតជាប៊ីលានរៀល
1,000
800
600
400
200
0
មករា
មេសា
កក្កដា
តុលា
ពន្ធលើប្រាក់ចំណូលនិងប្រាក់ចំណេញ ២០១៨
ពន្ធលើទំនិញ និងសេវាប្រើប្រាស់ ២០១៨
ពន្ធលើពាណិជ្ជកម្មអន្តរជាតិ ២០១៨
ពន្ធលើប្រាក់ចំណូល និងប្រាក់ចំណេញ ២០១៧
ពន្ធលើទំនិញ និងទំនិញប្រើប្រាស់ ២០១៧
ពន្ធលើពាណិជ្ជកម្មអន្តរជាតិ ២០១៧


ក្រាហ្វិកទី ៤÷ ចំណាយសរុប
ឯកតា÷ ពិតជាប៊ីលានរៀល
1,600
1,400
1,200
1,000
800
600
400
200
0
មករា
មេសា
កក្កដា
តុលា
ចំណាយ ២០១៨
ទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ ២០១៨
ចំណាយ ២០១៧
ទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ ២០១៧

# ៣. ក្រាហ្វិក


ក្រាហ្វិកទី ៥÷ ចំណាយ
ឯកតា÷ ពិតជាប៊ីលានរៀល
1,000
900
800
700
600
500
400
300
200
100
0
មករា
មេសា
កក្កដា
តុលា
ចំណាយបន្ទុកបុគ្គលិក ២០១៨
ចំណាយមិនមែនបន្ទុកបុគ្គលិក ២០១៨
ចំណាយបន្ទុកបុគ្គលិក ២០១៧
ចំណាយមិនមែនបន្ទុកបុគ្គលិក ២០១៧


ក្រាហ្វិកទី ៦÷ ប្រតិបត្តិការទ្រព្យសកម្ម និងបំណុល
ឯកតា÷ ពិតជាប៊ីលានរៀល
1,000
500
0
-500
-1,000
មករា
មេសា
កក្កដា
តុលា
ទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុសុទ្ធ ២០១៨
ទ្រព្យសកម្មហិរញ្ញវត្ថុសុទ្ធ ២០១៨
បំណុលសុទ្ធ ២០១៨
ទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុសុទ្ធ ២០១៧
ទ្រព្យសកម្មហិរញ្ញវត្ថុសុទ្ធ ២០១៧
បំណុលសុទ្ធ ២០១៧


ក្រាហ្វិកទី ៧÷ ទ្រព្យសកម្មហិរញ្ញវត្ថុ
ឯកតា÷ ពិតជាប៊ីលានរៀល
1,000
800
600
400
200
0
-200
-400
-600
-800
មករា
មេសា
កក្កដា
តុលា
រូបិយប័ណ្ណ និងប្រាក់បញ្ញើ ២០១៨
មិនមែនរូបិយប័ណ្ណ និងប្រាក់បញ្ញើ ២០១៨
រូបិយប័ណ្ណ និងប្រាក់បញ្ញើ ២០១៧
មិនមែនរូបិយប័ណ្ណ និងប្រាក់បញ្ញើ ២០១៧


ក្រាហ្វិកទី ៨÷ បំណុល
ឯកតា÷ ពិតជាប៊ីលានរៀល
400
300
200
100
0
-100
-200
-300
-400
-500
មករា
មេសា
កក្កដា
តុលា
កម្ចី ២០១៨
មិនមែនកម្ចី ២០១៨
កម្ចី ២០១៧
មិនមែនកម្ចី ២០១៧

# ៤.ខ្ទបសម្ព័ន្ធស្ថិតិហិរញ្ញវត្ថុរដ្ឋាភិបាលថ្នាក់ក្រោមជាតិ

ឯកតា÷ លានរៀល

| | | អនុវត្តន៍<br>២០១៥ | អនុវត្តន៍<br>២០១៦ | អនុវត្តន៍<br>២០១៧ | អនុវត្តន៍<br>ឆមាសទី១ ឆ្នាំ២០១៨ |
|---|---|---|---|---|---|
| | វិធីសាស្ត្រគណនេយ្យ | Non Cash | Non Cash | Non Cash | Non Cash |
| **1** | **ចំណូល** | **1,449,977.4** | **1,444,774.2** | **1,798,487.9** | **981,894.9** |
| 11 | ពន្ធ | 761,372.3 | 755,258.1 | 1,009,595.3 | 510,434.8 |
| 12 | ការចូលរួមពីសង្គម | … | … | … | 0.0 |
| 13 | អំណោយ | 634,297.1 | 635,351.4 | 747,368.7 | 454,805.5 |
| 14 | ចំណូលផ្សេងៗ | 54,308.0 | 54,164.7 | 41,523.9 | 16,654.6 |
| **2** | **ចំណាយ** | **974,628.8** | **1,078,847.2** | **1,385,663.6** | **413,625.6** |
| 21 | បន្ទុកបុគ្គលិក | 225,075.1 | 308,999.5 | 332,644.7 | 180,899.8 |
| 22 | ទំនិញ និងសេវាកម្ម | 684,972.7 | 696,590.9 | 830,433.0 | 169,305.1 |
| 23 | ការប្រើប្រាស់ទុនអចល័ត | … | … | … | 0.0 |
| 24 | ការប្រាក់ | … | … | … | 0.0 |
| 25 | ឧបត្ថម្ភកធន | … | … | … | 0.0 |
| 26 | អំណោយ | 42.1 | 42.9 | 130,509.4 | 15,288.2 |
| 27 | ឧបត្ថម្ភសង្គមកិច្ច | 9,708.6 | 11,504.4 | 16,043.6 | 6,813.7 |
| 28 | ចំណាយផ្សេងៗ | 54,830.4 | 61,709.5 | 76,032.8 | 41,318.7 |
| ***GOB*** | ***តុល្យភាពប្រតិបត្តិការដុល*** | **475,348.6** | **365,927.1** | **412,824.3** | **568,269.3** |
| ***NOB*** | ***តុល្យភាពប្រតិបត្តិការសុទ្ធ*** | **475,348.6** | **365,927.1** | **412,824.3** | **568,269.3** |
| | **ប្រតិបត្តិការទ្រព្យមិនមែនហិរញ្ញវត្ថុ** | | | | 0.0 |
| **31** | **ទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុសុទ្ធ** | 313,219.4 | 294,622.4 | 305,047.1 | 128,091.0 |
| 311 | ទ្រព្យអចល័ត | 311,694.1 | 276,672.4 | 305,007.7 | 127,859.8 |
| 312 | បម្រែបម្រួលសន្និធិ | … | … | … | 0.0 |
| 313 | វត្ថុមានតម្លៃ | … | … | … | 0.0 |
| 314 | ទ្រព្យសកម្មគ្មានផលិតភាព | 1,525.3 | 17,950.0 | 39.4 | 231.2 |
| ***2M*** | ***ចំណាយសរុប*** | 1,287,848.2 | 1,373,469.6 | 107,777.2 | 541,716.6 |
| ***NLB*** | ***សមតុល្យនៃការអោយខ្ចី/ប្រាក់កម្ចី*** | **162,129.2** | **71,304.7** | **107,777.2** | **440,178.3** |
| | **ប្រតិបត្តិការទ្រព្យហិរញ្ញវត្ថុ និង បំណុល (ហិរញ្ញប្បទាន)** | | | | 0.0 |
| **32** | **ទ្រព្យហិរញ្ញវត្ថុសុទ្ធ** | 271,748.2 | 52,119.5 | 227,152.6 | 208,324.0 |
| 321 | ក្នុងប្រទេស | 271,748.2 | 52,119.5 | 227,152.6 | 208,324.0 |
| 322 | ក្រៅប្រទេស | … | … | … | 0.0 |
| **33** | **បំណុលសុទ្ធ** | 109,619.0 | -19,183.6 | 121,270.8 | -208,558.9 |
| 331 | ក្នុងប្រទេស | 109,619.0 | -19,183.6 | 121,270.8 | -208,558.9 |
| 332 | ក្រៅប្រទេស | … | … | … | 0.0 |

## ៤.សេចក្តីសង្ខេបស្តីអំពី "ក្របខ័ណ្ឌស្តង់ដារស្ថិតិហិរញ្ញវត្ថុរដ្ឋាភិបាល"

## អនុលោមទៅតាម Government Finance Statistics (GFSM2014)

### 1. របាយការណ៍ប្រតិបត្តិការហិរញ្ញវត្ថុរដ្ឋាភិបាល

1.1. **របាយការណ៍ប្រតិបត្តិការហិរញ្ញវត្ថុរដ្ឋាភិបាល** ជារបាយការណ៍មួយដែលបង្ហាញយ៉ាងលម្អិតតាមរយៈប្រតិបត្តិការសំខាន់ៗ ដូចជា÷ ចំណូល, ចំណាយ, វិនិយោគសុទ្ធលើទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ, វិនិយោគសុទ្ធលើទ្រព្យសកម្មហិរញ្ញវត្ថុ, និងបំណុលសុទ្ធ។ ផ្អែកលើក្របខ័ណ្ឌស្តង់ដារស្ថិតិហិរញ្ញវត្ថុរដ្ឋាភិបាលនេះ **ចំណូល** គឺជាប្រតិបត្តិការ (transaction) ដែលធ្វើឱ្យតម្លៃសុទ្ធនៃទ្រព្យកម្ម (net worth) កើនឡើង។ រីឯ**ចំណាយ** គឺជាប្រតិបត្តិការ (transactions) ដែលធ្វើឱ្យតម្លៃសុទ្ធនៃទ្រព្យកម្មថយចុះ។ **ការវិនិយោគសុទ្ធលើទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ**គឺជាលទ្ធផលនៃអចលនទ្រព្យ (fixed assets) បូកសន្និធិសុទ្ធ, ទ្រព្យមានតម្លៃសុទ្ធ និងទ្រព្យគ្មានផលិតភាពសុទ្ធ (non-produce assets) ។

1.2. នៅក្នុងរបាយការណ៍ប្រតិបត្តិការហិរញ្ញវត្ថុរដ្ឋាភិបាលមានតុល្យភាពចំនួន ០២ ដែលជាធាតុដ៏សំខាន់ក្នុងកិច្ចការវិភាគ។ តុល្យភាពទី១ គឺជាផលសងនៃចំណូល និងចំណាយ ដែលហៅថា **តុល្យភាពប្រតិបត្តិការសុទ្ធ** និងតុល្យភាពទី២ គឺជាផលសងនៃតុល្យភាពប្រតិបត្តិការសុទ្ធ និងការវិនិយោគលើទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុសុទ្ធ ដែលហៅថា **តុល្យភាពការឱ្យខ្ចី/ប្រាក់កម្ចីសុទ្ធ**។ តុល្យភាពទី២នេះ ក៏អាចបង្ហាញតាមរយៈផលសងនៃការវិនិយោគសុទ្ធលើទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលសុទ្ធ។

1.3. **តុល្យភាពប្រតិបត្តិការសុទ្ធ** ទិន្នន័យតុល្យភាពនេះអាចយកទៅប្រៀបធៀបជាមួយគណនីជាតិតាមរយៈការបូកបញ្ចូលគ្នានៃការសន្សំនិងមូលនិធិផ្ទេរដែលត្រូវទទួល។ **តុល្យភាពប្រតិបត្តិការសុទ្ធ**នៅទីនេះមិនបានរាប់បញ្ចូលចំណេញ ឬខាតដែលកើតចេញពី ការប្រែប្រួលថ្លៃ (change in price level) និងការប្រែប្រួលជាបរិមាណ (other change in the volume)ទ្រព្យសកម្ម ឬបំណុលឡើយ។ គោលនយោបាយរបស់ រដ្ឋាភិបាលមានឥទ្ធិពលផ្ទាល់លើប្រតិបត្តិការដែលធ្វើឱ្យតម្លៃសុទ្ធនៃទ្រព្យប្រែប្រួលព្រោះតែរដ្ឋាភិបាលជាអ្នកគ្រប់គ្រងដោយផ្ទាល់លើសេចក្តីសម្រេចចិត្តចំពោះគ្រប់ប្រតិបត្តិការទាំងអស់។ ចំណេញ ឬខាតចេញពីការប្រែប្រួលតម្លៃសុទ្ធនៃទ្រព្យសកម្ម ឬបំណុល(ប្រែប្រួលថ្លៃទីផ្សារ)និងការប្រែប្រួលជាបរិមាណ (ដោយសារព្រឹត្តិការណ៍ណាមួយ) គឺមិនស្ថិតនៅក្រោមការគ្រប់គ្រងដោយផ្ទាល់របស់រដ្ឋាភិបាលឡើយ តែរដ្ឋាភិបាលអាចមានយន្តការ ឬគោលនយោបាយដើម្បីកាត់បន្ថយផលប៉ះពាល់ដែលកើតចេញពីការប្រែប្រួលខាងលើឱ្យស្ថិតក្នុងកម្រិតអប្បរមា។

1.4. **តុល្យភាពការឱ្យខ្ចី/ប្រាក់កម្ចីសុទ្ធ** ដែលបង្ហាញឱ្យឃើញពីការប្រើប្រាស់ (វិនិយោគ) ធនធានហិរញ្ញវត្ថុទៅវិស័យខាងក្រៅទាំងសេដ្ឋកិច្ចក្នុងប្រទេស ឬក្រៅប្រទេស (ការឱ្យខ្ចី) ឬបង្ហាញឱ្យឃើញពីការទាញយកអត្ថប្រយោជន៍ប្រភពហិរញ្ញប្បទាន

ពីវិស័យខាងក្រៅទាំងសេដ្ឋកិច្ចក្នុងប្រទេស ឬក្រៅប្រទេស (ប្រាក់កម្ចី)។ តុល្យភាពនេះជាសូចនាករមួយដែលបង្ហាញឱ្យឃើញពីឥទ្ធិពលនៃសកម្មភាពហិរញ្ញវត្ថុរបស់រដ្ឋាភិបាលទៅលើសេដ្ឋកិច្ចទាំងក្នុង និងក្រៅប្រទេស។

**1.5. តុល្យភាពប្រតិបត្តិការដុល÷** មានភាពខុសគ្នាពីតុល្យភាពប្រតិបត្តិការសុទ្ធនៅត្រង់ថាតុល្យភាពប្រតិបត្តិការដុលមិនបានរួមបញ្ចូលនូវចំណាយលើការប្រើប្រាស់(រំលោះ)ទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុឡើយ។ ចំណាយលើការប្រើប្រាស់ទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុមានភាពលំបាកក្នុងការវាយតម្លៃ។ ប្រសិនបើតុល្យភាពប្រតិបត្តិការដុលធំជាងតុល្យភាពប្រតិបត្តិការសុទ្ធនេះមានន័យថាចំណាយលើការប្រើប្រាស់លើទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុត្រូវបានកត់ត្រា។

**1.6. ចំណាយសរុប** (expenditure) គឺជាលទ្ធផលដែលបានមកពីចំណាយ (expenses) និងវិនិយោគ (ការទិញ/ដោះដូរ)លើទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ។ ចំណាយសរុបនេះបានរួមបញ្ចូលទាំងចំណាយលើការប្រើប្រាស់ទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុមានភាពសមស្របសម្រាប់ការប្រៀបធៀបជាមួយបណ្តាប្រទេសផ្សេងៗ បើទោះបីជាការវាយតម្លៃចំណាយរំលោះនៅមិនទាន់មានសង្គតិភាពនៅឡើយក៏ដោយ។

**1.7. ចំណូល** គឺជាប្រតិបត្តិការ (transaction) ដែលធ្វើឱ្យតម្លៃសុទ្ធនៃទ្រព្យកើនឡើង។ ធាតុសំខាន់ៗនៃចំណូលរួមមាន÷ ចំណូលពន្ធ (១១), ចំណូលពីការចូលរួមសង្គម (១២), ចំណូលពីអំណោយ (១៣), និងចំណូលផ្សេងៗ (១៤) ។ ចំណូលដែលបានមកពីការលក់ទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុដែលប្រើប្រាស់រួច (ជម្រុះបញ្ជី) មិនត្រូវបានទទួលស្គាល់ជាចំណូលឡើយ ពីព្រោះវាមិនបានធ្វើឱ្យមានការប្រែប្រួលតម្លៃសុទ្ធនៃទ្រព្យសកម្មនោះទេ។ អ្វីដែលប្រែប្រួលចេញពីប្រតិបត្តិការនេះគឺ ការប្រែប្រួលសមាសធាតុដែលមាននៅក្នុងតារាងតុល្យភាពតែប៉ុណ្ណោះ ពោលគឺទ្រព្យសកម្មមួយថយចុះ (ទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ)ហើយ ទ្រព្យសកម្មផ្សេងកើនឡើង (សាច់ប្រាក់)។ ដូចគ្នាដែរសម្រាប់ប្រាក់កម្ចីដែលទទួលបានឬការសងបំណុលដែលគេជំពាក់ ក៏មិនត្រូវបានចាត់ទុកជាចំណូលដែរ។

**1.8. ចំណាយ** គឺជាប្រតិបត្តិការ (transaction)ដែលធ្វើឱ្យតម្លៃសុទ្ធនៃទ្រព្យថយចុះ។ ធាតុសំខាន់ៗនៃចំណាយ រួមមាន÷ ចំណាយប្រាក់បៀវត្ស និងលាភការ (២១), ចំណាយការប្រើប្រាស់ទំនិញ និងសេវាកម្ម (២២), ចំណាយលើការប្រាក់ (២៤) ,ចំណាយលើការឧបត្ថម្ភធន (២៥), ចំណាយលើអំណោយ (២៦) ចំណាយលើឧបត្ថម្ភសង្គមកិច្ច (២៧), និងចំណាយផ្សេងៗ(២៨)។ មិនត្រឹមតែប៉ុណ្ណោះ ចំណាយក៏ត្រូវបានធ្វើចំណាត់ថ្នាក់ ទៅតាមមុខងាររបស់រដ្ឋាភិបាលផងដែរ ដូចជា÷ ចំណាយលើសុខភាព ឬកិច្ចការពារសង្គមជាដើម។ ការទិញ ឬដោះដូរទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ មិនត្រូវបានចាត់ទុកជាចំណាយឡើយ ពីព្រោះវាមិនបានធ្វើឱ្យមានការប្រែប្រួលតម្លៃសុទ្ធនៃទ្រព្យឡើយ។ ការប្រែប្រួលកើតចេញពីប្រតិបត្តិការខាងលើនេះគឺ ការប្រែប្រួលសមាសធាតុដែលមាននៅក្នុងតារាងតុល្យភាពតែប៉ុណ្ណោះ។ ដូចគ្នាដែរសម្រាប់ប្រាក់កម្ចីដែលបានសង ក៏មិនត្រូវបានចាត់ទុកជាចំណាយដែរ។

1.9. ផ្នែកទី៣នៃរបាយការណ៍ប្រតិបត្តិការហិរញ្ញវត្ថុរដ្ឋាភិបាលនេះ គឺជា**ប្រតិបត្តិការហិរញ្ញវត្ថុ** ទាំងឡាយដែលធ្វើឱ្យមានបម្រែបម្រួលទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុល។ ប្រតិបត្តិការហិរញ្ញវត្ថុត្រូវបានធ្វើចំណាត់ថ្នាក់ដោយផ្អែកលើដៃគូ (counterpart) ដែលបានជំពាក់ (ទាំងក្នុង និងក្រៅប្រទេស) ទាំងក្នុងទ្រព្យសកម្ម និងបំណុល។

1.10. បន្ថែមលើចំណាត់ថ្នាក់ខាងលើ ប្រតិបត្តិការទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលក៏ត្រូវបានធ្វើចំណាត់ថ្នាក់ដោយផ្អែកលើប្រភេទឧបករណ៍ហិរញ្ញវត្ថុដែលមានដូចជា÷ រូបិយវត្ថុ មាស និងអេសឌីអា, រូបិយប័ណ្ណ និងប្រាក់បញ្ញើ, មូលបត្របំណុល, កម្ចី, ដើមទុន និងមូលនិធិភាគហ៊ុន, ធានារ៉ាប់រង សោធន និងកញ្ចប់ធានារ៉ាប់រង, ដេរីវេទីវហិរញ្ញវត្ថុ និងភាគហ៊ុនបុគ្គលិក, គណនីត្រូវទទួល/ត្រូវសងផ្សេងៗ។ មិនត្រឹមតែប៉ុណ្ណោះប្រតិបត្តិការទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលក៏ត្រូវបានធ្វើចំណាត់ថ្នាក់ដោយផ្អែកលើវិស័យដែលជាដៃគូបដិភាគនៃឧបករណ៍ហិរញ្ញវត្ថុដូចជា÷ សាជីវកម្មហិរញ្ញវត្ថុ, សាជីវកម្មមិនមែនហិរញ្ញវត្ថុ, គេហកិច្ច (household) និងស្ថាប័នមិនស្វែងរកប្រាក់ចំណេញ។

1.11. មធ្យោបាយម្យ៉ាងទៀត នៃការធ្វើចំណាត់ថ្នាក់ប្រតិបត្តិការទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុល គឺដោយផ្អែកលើការកើនឡើងថ្មី ឬក៏ការជម្រះចេញ ដែលបម្រើឱ្យគោលដៅនយោបាយ ឬក៏ផ្អែកលើការគ្រប់គ្រងសន្ទនីភាព។ ភាពខុសគ្នានោះនៅត្រង់ថាវាមិនត្រូវបានរាប់បញ្ចូលក្នុងរបាយការណ៍ប្រតិបត្តិការហិរញ្ញវត្ថុរដ្ឋាភិបាលទេ តែវាត្រូវប្រើសម្រាប់កំណត់តុល្យភាពសារពើពន្ធ។

1.12. គោលនយោបាយសាធារណៈដែលទាក់ទងទៅនឹងទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលអាចត្រូវបានលើកមកគិតគូរក្នុងហេតុផលផ្សេងៗ ដូចជាការជម្រុញឧស្សាហកម្មថ្មី, ជួយសង្គ្រោះសាជីវកម្មសាធារណៈ, ឬក៏ជួយអាជីកម្មណាមួយដើម្បីឱ្យមានភាពសម្បូរបែបក្នុងសេដ្ឋកិច្ច។ ប្រតិបត្តិការទាំងនេះអាចមានទម្រង់ផ្សេងៗគ្នាដូចជា÷ កម្ចី, មូលបត្រដើមទុន ឬមូលបត្របំណុលជាដើម។ ជាមួយគ្នានេះដែរ ប្រតិបត្តិការខាងលើក៏អាចមានផងដែរក្នុងទម្រង់ជាសម្បទាន។

1.13. ប្រតិបត្តិការទ្រព្យសកម្មហិរញ្ញវត្ថុផ្សេងៗទៀត គឺត្រូវបានសន្មត់ថាជាការគ្រប់គ្រងសន្ទនីភាពឬក៏គោលបំណងផ្សេង។ ដែលនេះបង្ហាញថាទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានគ្រប់គ្រងដោយបានទាញយកផលប្រយោជន៍ស្របតាមអត្រាទីផ្សារ ព្រមទាំងធានាបាននូវមូលនិធិគ្រប់គ្រាន់សម្រាប់ប្រតិបត្តិការប្រចាំថ្ងៃ ឬគ្រប់គ្រាន់ជាមួយតម្រូវការសង្គមនៅពេលខាងមុខដូចជាមូលនិធិពិសេសរបស់រដ្ឋាភិបាលជាដើម។